ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚៚៚❋៛៛៛៛៛

ក្រសួងអប់រំ យុវជន និងកីឡា

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

# របាយការណ៍
# បូកសរុបការងារវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្ដមសិក្សា
# ចាប់ពីឆ្នាំ២០១៩ ដល់ ឆ្នាំ២០២៣

តុលា ២០២៤

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. គោលបំណងនៃការវាយតម្លៃ ........ 1

៣. វិសាលភាពនៃការវាយតម្លៃ........ 1

៤. ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា........ 1

៤. ដំណើរការ និង នីតិវិធីនៃការវាយតម្លៃ........2

៥. លទ្ធផលវាយតម្លៃ........3

៦. ផលជះ........3

# តារាង ក្រាហ្វិក ដ្យាក្រាម

តារាង១ ៖ កម្រិតពិន្ទុមធ្យមភាគសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំ ........................................................ 2
តារាង២ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំ ........................................................ 3

## ១. សេចក្តីផ្តើម

ចាប់តាំងពីស្តង់ដាជាតិ សម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានអនុម័តនាថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) បានចុះវាយតម្លៃសាកល្បងលើគ្រឹះស្ថានឧត្តមសិក្សាចំនួន ៥៤ ដើម្បីពិនិត្យមើលស្ថានភាពជាក់ស្តែងនិងការអនុវត្តស្តង់ដាជាតិ ក្នុងឆ្នាំ២០១៥ ២០១៦ និង ២០១៧។ ក្រោយពេលធ្វើការវាយតម្លៃសាកល្បងនេះ គ.ទ.ក ទទួលបាននូវទិន្នន័យនិងមតិរិះគន់មួយចំនួន ដូចជា ភាពលម្អៀងក្នុងការដាក់ពិន្ទុ និងការពុំមានសង្គតិភាពរវាងក្រុមមន្រ្តីវាយតម្លៃផ្សេងៗគ្នា។ ដើម្បីធានាបាននូវភាពមិនលម្អៀងក្នុងការដាក់ពិន្ទុ និងសង្គតិភាព រវាងក្រុមមន្រ្តីវាយតម្លៃផ្សេងៗគ្នា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាបានរៀបចំសៀវភៅណែនាំ ស្តីពីការអនុវត្តស្តង់ដាជាតិ និងនិទ្ទេសបទសម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ដែលដាក់ឱ្យអនុវត្តដោយសេចក្តីណែនាំលេខ ០១/១៩ គ.ទ.ក សណន ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩។

សៀវភៅណែនាំ ស្តីពីការអនុវត្តស្តង់ដាជាតិនិងនិទ្ទេសបទសម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ត្រូវបានបញ្ចប់នៅដំណាច់ឆ្នាំ២០២៣ និងបានបន្តដាក់ឱ្យអនុវត្តសៀវភៅណែនាំនិងនិទ្ទេសបទថ្មី (ដែលមានកម្រិត១០ពិន្ទុ) តាមសេចក្តីណែនាំលេខ ០១/២៣ គ.ទ.ក សណន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣។

## ២. គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃនេះធ្វើឡើងក្នុងគោលបំណង ដើម្បីផ្តល់កម្រិតនៃការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ដោយប្រើប្រាស់ស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា សេចក្តីណែនាំស្តីពីដំណើរការទទួលស្គាល់គុណភាពអប់រំ សៀវភៅណែនាំស្តីពីការអនុវត្តស្តង់ដាជាតិ និងនិទ្ទេសបទសម្រាប់ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា សៀវភៅណែនាំមន្រ្តីវាយតម្លៃស្តីពីការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និង ឧបករណ៍វាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។ លទ្ធផលវាយតម្លៃត្រូវបានប្រើប្រាស់សម្រាប់ការលើកកម្ពស់គុណភាពអប់រំ និងផ្តល់កម្រិតនៃការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

## ៣. វិសាលភាពនៃការវាយតម្លៃ

ការវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា អនុវត្តលើគ្រឹះស្ថានឧត្តមសិក្សាដែលបណ្តុះបណ្តាលចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤. ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបីកម្រិតគឺ ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន និង ការទទួលស្គាល់គុណភាពអប់រំជាបេក្ខភាព។

លទ្ធផលនៃការវាយតម្លៃសម្រាប់ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវផ្តល់ជូនគ្រឹះស្ថានឧត្តមសិក្សា ដោយយកពិន្ទុមធ្យមភាគសរុបនៃស្តង់ដាជាតិទាំងប្រាំបួនជាមូលដ្ឋាន។ ប្រសិនបើគ្រឹះស្ថានឧត្តមសិក្សាទទួលបានពិន្ទុមធ្យមភាគសរុបនៃស្តង់ដាជាតិទាំងប្រាំបួនពី ៣.៥០ ដល់ ៥.០០ ទទួលបានការទទួល

ស្គាល់គុណភាពអប់រំពេញសិទ្ធ (៥ឆ្នាំ) ប្រសិនបើទទួលបានពិន្ទុមធ្យមភាគសរុបពី ២.៥០ ដល់ ៣.៤៩ ទទួលបានការទទួលស្គាល់គុណភាពអប់រំបណ្ដោះអាសន្ន (៣ឆ្នាំ) និង ប្រសិនបើទទួលបានពិន្ទុមធ្យមភាគសរុបពី ១.០០ ដល់ ២.៤៩ ទទួលបានការទទួលស្គាល់គុណភាពអប់រំបណ្ដោះអាសន្ន (២ឆ្នាំ)។

*តារាង១ ៖ កម្រិតពិន្ទុមធ្យមភាគសម្រាប់ផ្ដល់ការទទួលស្គាល់គុណភាពអប់រំ*

| ល.រ | ពិន្ទុមធ្យមភាគសរុប | ការទទួលស្គាល់គុណភាពអប់រំ |
|---|---|---|
| ១ | ៣.៥០ ដល់ ៥.០០ | ពេញសិទ្ធិ (៥ឆ្នាំ) |
| ២ | ២.៥០ ដល់ ៣.៤៩ | បណ្ដោះអាសន្ន (៣ឆ្នាំ) |
| ៣ | ១.០០ ដល់ ២.៤៩ | បេក្ខភាព (២ឆ្នាំ) |

## ៤. ដំណើរការ និង នីតិវិធីនៃការវាយតម្លៃ

ការវាយតម្លៃនេះនឹងអនុវត្តតាមនីតិវិធីរបស់ គ.ទ.ក. ដោយប្រើប្រាស់ស្តង់ដាជាតិ និង ក្រុមមន្ត្រីវាយតម្លៃ គ.ទ.ក។ ដើម្បីធានាថាដំណើរការវាយតម្លៃប្រព្រឹត្តទៅប្រកបដោយសង្គតិភាព ប្រសិទ្ធិភាព តម្លាភាព និង គណនេយ្យភាព ក្រុមមន្ត្រីវាយតម្លៃតម្រូវឲ្យចុះកិច្ចព្រមព្រៀងការងារជាមួយ គ.ទ.ក. មុននឹងចាប់ផ្តើមចុះវាយតម្លៃ។ មន្ត្រីវាយតម្លៃអាចប្រើប្រាស់ឧបករណ៍ប្រមូលវិភាគទិន្នន័យនិងព័ត៌មាន និងនិទ្ទេសបទ ដើម្បីស្វែងរកចំណុចខ្លាំង ចំណុចកែលម្អ និងផ្តល់អនុសាសន៍ដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការកែលម្អគុណភាពអប់រំ។

ដំណើរការវាយតម្លៃប្រព្រឹត្តទៅជាបីដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលទី១ ៖** ក្រុមមន្ត្រីវាយតម្លៃគុណភាពអប់រំឧត្តមសិក្សា សិក្សារបាយការណ៍ស្វ័យវាយតម្លៃ និងឯកសារឧបសម្ព័ន្ធរបស់គ្រឹះស្ថានឧត្តមសិក្សា ដែលមានរយៈពេល៣ថ្ងៃ ដើម្បីសិក្សាពីចំណុចខ្លាំងនិងចំណុចខ្វះខាត និងកំណត់ព័ត៌មានចាំបាច់ផ្សេងៗទៀតដែលត្រូវស្នើសុំឱ្យគ្រឹះស្ថានឧត្តមសិក្សាបញ្ជាក់បន្ថែមនៅពេលក្រុមការងារចុះវាយតម្លៃផ្ទាល់នៅគ្រឹះស្ថានឧត្តមសិក្សា។

**ដំណាក់កាលទី២ ៖** ក្រុមមន្ត្រីវាយតម្លៃចុះវាយតម្លៃលើការអនុវត្តផ្ទាល់នៅគ្រឹះស្ថានឧត្តមសិក្សា ដោយធ្វើការសម្ភាស ការពិភាក្សា ការស្ទង់មតិ ការពិនិត្យជាក់ស្តែង និង ការអង្កេតផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលរបាយការណ៍ស្វ័យវាយតម្លៃជាមួយនឹងការអនុវត្តជាក់ស្តែងរបស់គ្រឹះស្ថានឧត្តមសិក្សា។ ដំណាក់កាលទី២នេះ បានប្រព្រឹត្តទៅអស់រយៈពេល៥ថ្ងៃ។ ក្នុងដំណើរការវាយតម្លៃ ក្រុមការងារបានធ្វើការស្ទង់មតិ ជួបប្រជុំ និង សម្ភាសជាមួយភាគីពាក់ព័ន្ធរួមមាន ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងនិងបុគ្គលិកនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា គណៈកម្មការនានា និស្សិតកំពុងសិក្សា អតីតនិស្សិតដែលទើបបញ្ចប់ការសិក្សារយៈពេល៣ឆ្នាំចុងក្រោយ បុគ្គលិកអប់រំ តំណាងនិយោជក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ នៅថ្ងៃបញ្ចប់នៃការចុះវាយតម្លៃ ក្រុមមន្ត្រីវាយតម្លៃមានភារកិច្ចប្រជុំបូកសរុបលទ្ធផលបឋមនៃការវាយតម្លៃ ដើម្បីបង្ហាញជូនគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាបានជ្រាប។ ក្នុងឱកាសនេះ គ្រឹះស្ថានឧត្តមសិក្សាមានសិទ្ធិពន្យល់បកស្រាយ និង បង្ហាញភស្តុតាងបន្ថែម ដើម្បីការពារលទ្ធផលស្វ័យវាយតម្លៃរបស់ខ្លួន។

**ដំណាក់កាលទី៣ ៖** ក្រោយពេលបញ្ចប់ការចុះវាយតម្លៃនៅគ្រឹះស្ថានឧត្តមសិក្សា ក្រុមមន្ត្រីវាយតម្លៃត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះវាយតម្លៃជាក់ជូនអគ្គលេខាធិការដ្ឋាន គ.ទ.ក។ របាយការណ៍

លទ្ធផលវាយតម្លៃនេះត្រូវបញ្ជូនទៅគ្រឹះស្ថានឧត្តមសិក្សាសាមី ដើម្បីផ្ទៀងផ្ទាត់លើទិន្នន័យ និងព័ត៌មានដែលទទួលបានពីការវាយតម្លៃ មុននឹងដាក់ជូន គ.ទ.ក ពិនិត្យ និង សម្រេចជាចុងក្រោយ។ ក្នុងករណីមានការកែតម្រូវលើរបាយការណ៍នេះ គ្រឹះស្ថានឧត្តមសិក្សាត្រូវសរសេរលិខិតផ្លូវការជូន គ.ទ.ក ក្នុងរយៈពេលមិនលើសពី២សប្តាហ៍។

## ៥. លទ្ធផលវាយតម្លៃ

ចាប់តាំងពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៣ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា បានធ្វើការវាយតម្លៃនិងផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាចំនួន ៣៩ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន ១៦ និង គ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន ២៣។ ក្នុងចំណោម ៣៩ គ្រឹះស្ថានឧត្តមសិក្សា មានគ្រឹះស្ថានឧត្តមសិក្សារដ្ឋបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិចំនួន ១៦ គ្រឹះស្ថានឧត្តមសិក្សាឯកជនបានទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិចំនួន ២២ និង គ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន ១ បានការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន (ឧបសម្ព័ន្ធ១ ២ ៣ និង ៤)។

*តារាង២ ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំ*

| ឆ្នាំ | ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំ | | |
|---|---|---|---|
| | រដ្ឋ | ឯកជន | សរុប |
| ២០១៩ | ៥ | ៥ | ១០ |
| ២០២០ | - | - | - |
| ២០២១ | ៤ | ៦ | ១០ |
| ២០២២ | ៦ | ៣ | ៩ |
| ២០២៣ | ១ | ៩ | ១០ |
| **សរុប** | **១៦** | **២៣** | **៣៩** |

## ៦. ផលវិជ្ជមាន

ឆ្លងកាត់ការវាយតម្លៃពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ គ្រឹះស្ថានឧត្តមសិក្សាបានបញ្ជាក់ថានីតិវិធីវាយតម្លៃបានភាពច្បាស់លាស់ ហ្មត់ចត់ និងតឹងរឹង ដោយនីតិវិធីប្រមូលទិន្នន័យនិងព័ត៌មានមានភាពច្បាស់លាស់ ដោយអនុវត្តទៅតាមឧបករណ៍វាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា និងប្រព្រឹត្តទៅនៅក្នុងរូបភាព៤ប្រភេទ រួមមាន ការពិនិត្យឯកសារ ការសង្កេត ការសម្ភាស និងការស្ទង់មតិតាមអនឡាញ។ កត្តាទាំងនេះធ្វើឱ្យលទ្ធផលនៃការវាយតម្លៃទទួលយកបាន ដោយបង្ហាញភស្តុតាងពិតប្រាកដ និងមានការពន្យល់ច្បាស់លាស់ ហើយមានគុណតម្លៃជំរុញឱ្យមានការអភិវឌ្ឍស្ថាប័ននិងលើកកម្ពស់គុណភាពអប់រំ។

លើសពីនេះយោងតាមលទ្ធផលវាយតម្លៃ លើការអនុវត្តនៃការវាយតម្លៃរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដោយ EU-SHARE ពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ គោលនយោបាយនិងការអនុវត្តរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានសង្គតិភាពជាមួយនឹងឧត្តមានុវត្តន៍ក្នុងតំបន់និងពិភពលោក និងគោលការណ៍ដែលបានចែងក្នុងក្របខណ្ឌធានាគុណភាពអាស៊ាន (AQAF) របស់បណ្តាញធានាគុណភាពអាស៊ាន (AQAN) ស្តង់ដានិងសៀវភៅណែនាំ

របស់សមាគមន៍ធានាគុណភាពអប់រំឧត្តមសិក្សាអឺរ៉ុប (ENQA) និងសៀវភៅណែនាំស្តីពីធានាគុណភាពអប់រំរបស់បណ្ដាញធានាគុណភាពអន្តរជាតិ (INQAAHE)។

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ជាសមាជិកពេញសិទ្ធិ របស់បណ្ដាញធានាគុណភាពអាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Quality Network-APQN) និង ជាសមាជិកពេញសិទ្ធ របស់បណ្ដាញធានាគុណភាពអាស៊ាន (ASEAN Quality Assurance Network-AQAN)។ រាល់សមាជិកបណ្ដាញធានាគុណភាពអាស៊ានត្រូវតែធ្វើការវាយតម្លៃការអនុវត្តការងាររបស់ខ្លួន ដើម្បីធានាថាការដាក់ចេញនូវគោលនយោបាយនិងការអនុវត្តមានសង្គតិភាពជាមួយនឹងឧត្តមានុវត្តន៍ក្នុងតំបន់និងពិភពលោក។ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាទទួលបានការវាយតម្លៃ ដោយ EU-SHARE ពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។

ឧបសម្ព័ន្ធ១

# បញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ លើគ្រឹះស្ថានឧត្តមសិក្សា៥ឆ្នាំ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣

List of HEIs is Received Full Accreditation for 5 Years (2019-2023)

| ល.រ<br>No. | ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា (រាជធានីភ្នំពេញ និងខេត្ត)<br>Name of HEIs (Phnom Penh & Province) | |
|---|---|---|
| | **គ្រឹះស្ថានឧត្តមសិក្សារដ្ឋ (៥)**<br>**Public HEIs (5 HEIs)** | **គ្រឹះស្ថានឧត្តមសិក្សាឯកជន (៥)**<br>**Private HEIs (5 HEIs)** |
| 1 | បណ្ឌិតសភានគរបាលកម្ពុជា<br>Police Academy of Cambodia<br>គ.ទ.ក. ០១០៨២០០១FA | សាកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ<br>American University of Phnom Penh<br>គ.ទ.ក. ០១១២២០០៦FA |
| 2 | សាកលវិទ្យាល័យជាតិគ្រប់គ្រង<br>National University of Management<br>គ.ទ.ក. ០១១២២០០៥FA | សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ<br>Phnom Penh International University<br>គ.ទ.ក. ០១១២២០០៨FA |
| 3 | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល<br>University of Health Sciences<br>គ.ទ.ក. ០១១២២០០៤FA | សាកលវិទ្យាល័យពុទ្ធិសាស្ត្រ<br>University of Puthisastra<br>គ.ទ.ក. ០១១២២០១០FA |
| 4 | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា<br>Institute of Technology of Cambodia<br>គ.ទ.ក. ០១១២២០០២FA | សាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>University of Economics and Finance<br>គ.ទ.ក. ០១១២២០០៩FA |
| 5 | វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ<br>National Institute of Business<br>គ.ទ.ក. ០១១២២០០៣FA | វិទ្យាស្ថានខេមអេដ<br>CamEd Institute<br>គ.ទ.ក. ០១១២២០០៧FA |

ឧបសម្ព័ន្ធ២

<table>
<tr><td colspan="3">បញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ<br>លើគ្រឹះស្ថានឧត្តមសិក្សា៥ឆ្នាំ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៤<br>List of HEIs is Received Full Accreditation for 5 Years (2020-2024)</td></tr>
<tr><td rowspan="2">ល.រ<br>No.</td><td colspan="2">ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា (រាជធានីភ្នំពេញ និងខេត្ត)<br>Name of HEIs (Phnom Penh & Province)</td></tr>
<tr><td>គ្រឹះស្ថានឧត្តមសិក្សារដ្ឋ (៤)<br>Public HEIs (4 HEIs)</td><td>គ្រឹះស្ថានឧត្តមសិក្សាឯកជន (៦)<br>Private HEIs (6 HEIs)</td></tr>
<tr><td>1</td><td>សាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>Royal University of Phnom Penh<br>គ.ទ.ក. ០១១២០១២១FA</td><td>សាកលវិទ្យាល័យអន្តរជាតិ (ទីតាំងគោល)<br>International University (Main Campus)<br>គ.ទ.ក. ០១១២០៨២១FA</td></tr>
<tr><td>2</td><td>សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច<br>Royal University of Law and Economics<br>គ.ទ.ក. ០១១២០៤២១FA</td><td>សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ<br>BELTEI International University<br>គ.ទ.ក. ០១១២០៧២១FA</td></tr>
<tr><td>3</td><td>សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ (ទីតាំងគោល)<br>National University of CHEASIM KAMCHAYMEAR (Main Campus)<br>គ.ទ.ក. ០១១៤១០២១FA</td><td>សាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន<br>PARAGON International University<br>គ.ទ.ក. ០១១២០៩២១FA</td></tr>
<tr><td>4</td><td>វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ<br>Health Science Institute of RCAF<br>គ.ទ.ក. ០១១២០៦២១FA</td><td>សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (ទីតាំងគោល)<br>Cambodian University for Specialties (Main Campus)<br>គ.ទ.ក. ០១១២០២២១FA</td></tr>
<tr><td>5</td><td></td><td>វិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា<br>ACLEDA Institute of Business<br>គ.ទ.ក. ០១១២០៣២១FA</td></tr>
<tr><td>6</td><td></td><td>វិទ្យាស្ថានវ៉ាន់ដា (ទីតាំងគោល)<br>VANDA Institute (Main Campus)<br>គ.ទ.ក. ០១១២០៥២១FA</td></tr>
</table>

ឧបសម្ព័ន្ធ៣

| បញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ<br>លើគ្រឹះស្ថានឧត្តមសិក្សា៥ឆ្នាំ ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦<br>List of HEIs is Received Full Accreditation for 5 Years (2022-2026) | | |
|---|---|---|
| ល.រ<br>No. | **ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា (រាជធានីភ្នំពេញ និងខេត្ត)**<br>Name of HEIs (Phnom Penh & Province) | |
| | **គ្រឹះស្ថានឧត្តមសិក្សារដ្ឋ (៦)**<br>**Public HEIs (6 HEIs)** | **គ្រឹះស្ថានឧត្តមសិក្សាឯកជន (៣)**<br>**Private HEIs (3 HIEs)** |
| 1 | សាកលវិទ្យាល័យជាតិបាត់ដំបង<br>National University of Battambang<br>គ.ទ.ក. ០១០២០៤២២FA | សាកលវិទ្យាល័យវេស្ទើន (ទីតាំងគោល)<br>Western University (Main Campus)<br>គ.ទ.ក. ០១១២០៧២២FA |
| 2 | សាកលវិទ្យាល័យស្វាយរៀង<br>SVAY RIENG University<br>គ.ទ.ក. ០១២០០៥២២FA | សាកលវិទ្យាល័យអង្គរ<br>Angkor University<br>គ.ទ.ក. ០១១៧០៨២២FA |
| 3 | សាកលវិទ្យាល័យហេងសំរិនត្បូងឃ្មុំ<br>University of HENG SAMRIN THBONGKHMUM<br>គ.ទ.ក. ០១២៥០៦២២FA | សាកលវិទ្យាល័យខេមរៈ (ទីតាំងគោល)<br>KHEMARAK University (Main Campus)<br>គ.ទ.ក. ០១១២០៩២២FA |
| 4 | វិទ្យាស្ថានជាតិអប់រំ<br>National Institute of Education<br>គ.ទ.ក. ០១១២០១២២FA | |
| 5 | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ<br>Phnom Penh Teacher Education College<br>គ.ទ.ក. ០១១២០២២២FA | |
| 6 | វិទ្យាស្ថានគរុកោសល្យបាត់ដំបង<br>Battambang Teacher Education College<br>គ.ទ.ក. ០១០២០៣២២FA | |

ឧបសម្ព័ន្ធ៣

<table>
<tr><th colspan="3">បញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិលើគ្រឹះស្ថានឧត្តមសិក្សា៥ឆ្នាំ ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧<br>List of HEIs is Received Full Accreditation for 5 Years (2023-2027)</th></tr>
<tr><th rowspan="2">ល.រ<br>No.</th><th colspan="2">ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា (រាជធានីភ្នំពេញ និងខេត្ត)<br>Name of HEIs (Phnom Penh & Province)</th></tr>
<tr><th>គ្រឹះស្ថានឧត្តមសិក្សារដ្ឋ (១)<br>Public HEIs (1 HEIs)</th><th>គ្រឹះស្ថានឧត្តមសិក្សាឯកជន (៨)<br>Private HEIs (8 HEIs)</th></tr>
<tr><td>1</td><td>សាកលវិទ្យាល័យ ជាតិមានជ័យ<br>National Meanchey University<br>គ.ទ.ក. ០១០១០១២៣FA</td><td>សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប<br>Asia Euro University<br>គ.ទ.ក. ០១១២០៣២៣FA</td></tr>
<tr><td>2</td><td></td><td>សាកលវិទ្យាល័យ សៅស៍អ៊ីសថ៍អេយសៀ<br>University of South-East Asia<br>គ.ទ.ក. ០១១៧០៤២៣FA</td></tr>
<tr><td>3</td><td></td><td>សាកលវិទ្យាល័យ ធនធានមនុស្ស<br>Human Resource University<br>គ.ទ.ក. ០១១២០៥២៣FA</td></tr>
<tr><td>4</td><td></td><td>សាកលវិទ្យាល័យ មេគង្គកម្ពុជា (ទីតាំងគោល)<br>Cambodian Mekong University (Main Campus)<br>គ.ទ.ក. ០១១២០២២៣FA</td></tr>
<tr><td>5</td><td></td><td>វិទ្យាស្ថាន វ៉ាន់ដា (សាខាខេត្តសៀមរាប)<br>Vanda Institute (Siem Reap Branch)<br>គ.ទ.ក. ០២១៧០៩២៣FA</td></tr>
<tr><td>6</td><td></td><td>វិទ្យាស្ថាន ប្រាយហូប<br>Bright Hope Institute<br>គ.ទ.ក. ០១០៤០៦២៣FA</td></tr>
<tr><td>7</td><td></td><td>សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា (សាខាខេត្តបាត់ដំបង)<br>Cambodian University for Specialties (Battambang Branch)<br>គ.ទ.ក. ០២០២០៧២៣FA</td></tr>
<tr><td>8</td><td></td><td>សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា (សាខាខេត្តសៀមរាប)<br>Cambodian University for Specialties (Siem Reap Branch)<br>គ.ទ.ក. ០២១៧០៨២៣FA</td></tr>
</table>

ឧបសម្ព័ន្ធ៤

## បញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាបានការទទួលស្គាល់គុណភាពអប់រំបណ្ដោះអាសន្ន លើគ្រឹះស្ថានឧត្តមសិក្សា៣ឆ្នាំ (២០២៣-២០២៥)

List of HEIs is Received Provisional Accreditation for 3 Years

| ល.រ<br>No. | ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា (រាជធានីភ្នំពេញ និងខេត្ត)<br>Name of HEIs (Phnom Penh & Province) | |
|---|---|---|
| | **គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ (0)**<br>Public HEIs (0 HEIs) | **គ្រឹះស្ថានឧត្តមសិក្សាឯកជន (១)**<br>Private HEIs (1 HEIs) |
| 1 | | វិទ្យាស្ថាន សិក្សាដើម្បីជោគជ័យ<br>Learning for Success Institute<br>គ.ទ.ក. ០១១២១០២៣PA |